# ព្រះរាជក្រឹត្យ

នស/រកត/០១១៨/០៥៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ជាករណីពិសេស ដល់មន្ត្រីរាជការ ១២ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព័ត៌មាន ៖

១- លោកជំទាវ **សន ម៉ារ៉ាដា** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ១
២- លោក **សំបូរ ន័រគៀ** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ១
៣- លោក **សំបូរ វណ្ណារិទ្ធ** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ១

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៤- លោក **រ៉ាត់ សោភា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៥- លោក **នៅ អ៊ិនឆ៉ាន់** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៦- លោក **សុ វណ្ណដេត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៧- លោក **ឆាម ច័ន្ទណារ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៨- លោក **គី ម៉ាលី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៩- លោក **យូ យ៉ិន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ១០- លោក **អន ខេមរិទ្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ១១- ឯកឧត្តម **ជា ច័ន្ទបរិបូរណ៍** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១២- លោកស្រី **រស់ ភណ្ឌារី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៧០១.០៥៩៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៨*

លេខ: ៥៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរកា ឆព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**